01154413

E336/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 09 / 10 / 2015
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម **Jean-Marc LAVERGNE** |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម **Claudia FENZ** |
| | ចៅក្រម **យូរ ឧត្តារា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៥ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | **សាធារណៈ** |

# សេចក្តីសម្រេចលើសំណើសុំរបស់មេធាវីការពារក្តី នួន ជា ពាក់ព័ន្ធនឹងការអនុវត្តរបស់ អង្គជំនុំជម្រះសាលាដំបូង នៅពេលសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី និង សាក្សី

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Marie GIRAUD

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE
គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

## ១. សេចក្តីផ្តើម និង សាវតារ

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើសុំមួយពីក្រុមមេធាវីការពារក្តី នួន ជា ("មេធាវីការពារក្តី") ពាក់ព័ន្ធនឹងការអនុវត្តមួយចំនួនក្នុងការសួរដេញដោលសាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណី[1]។ សំណើរបស់ នួន ជា លើកឡើងនូវការអនុវត្តជាទូទៅផង និង ជាលក្ខណៈពិសេសផងទាក់ទិននឹងការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-271។

២. ចំពោះការអនុវត្តទូទៅ មេធាវីការពារក្តីស្នើសុំថា ក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូង ៖ (១) មិនគប្បីអនុញ្ញាតឱ្យបង្ហាញចម្លើយពីមុនៗរបស់សាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២ មុនពេលសាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញខ្លួនដើម្បីផ្តល់សក្ខីកម្ម (២) ហាមឃាត់ភាគីមិនឱ្យសួរសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកជំនាញនូវសំណួរនាំមុខ ដែលមានបំណងឱ្យពួកគេបញ្ជាក់ពីភាពត្រឹមត្រូវនៃចម្លើយជាលាយលក្ខណ៍អក្សរពីមុនៗរបស់ពួកគេ (៣) ផ្តល់ឱកាសដល់មេធាវីការពារក្តីក្នុងការសួរដេញដោលទៅលើភាពត្រឹមត្រូវនៃភស្តុតាងរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកជំនាញ តាមរយៈការសួរតទល់គ្នា រួមទាំង ភាពអាចជឿជាក់បាន និង ភាពទុកចិត្តបាន និង (៤) កំណត់ថានៅពេលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានកោះហៅមកផ្តល់ភ័ស្តុតាងក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងអង្គហេតុនានា ក្រៅពីផលប៉ះពាល់ទៅលើជនរងគ្រោះ ឬ សំណង ពួកគេត្រូវស្បថមុននឹងផ្តល់សក្ខីកម្ម និង ផ្តល់ភ័ស្តុតាងដែលសហព្រះរាជអាជ្ញាជាអ្នកសួរដេញដោល[2]។

៣. ពាក់ព័ន្ធនឹងសក្ខីកម្មដោយឡែករបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-271 មេធាវីការពារក្តីស្នើអង្គជំនុំជម្រះសាលាដំបូងឱ្យ ៖ (១) កំណត់ថា ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-271 ផ្តល់សក្ខីកម្មដោយធ្វើសម្បថ ដោយសហព្រះរាជអាជ្ញាសួរដេញដោលដើមបណ្តឹងរូបនេះ (២) ហាមឃាត់មិនឱ្យដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-271 ពិនិត្យឡើងវិញនូវចម្លើយពីមុនៗរបស់ខ្លួន មុនពេលមកបង្ហាញខ្លួនដើម្បីផ្តល់សក្ខីកម្ម និង (៣) ផ្តល់ឱកាសដល់មេធាវីការពារក្តីក្នុងការសួរដេញដោលអំពី

[1] សំណើសុំរបស់ នួន ជា ពាក់ព័ន្ធនឹងការអនុវត្តមួយចំនួន នៅពេលសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-271 នាពេលខាងមុខ និង សាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងៗទៀតក្នុងសំណុំរឿង ០០២/០២ ឯកសារ E336 ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥ ("សំណើសុំរបស់ នួន ជា")។

[2] សំណើសុំរបស់ នួន ជា កថាខណ្ឌ ២០។

ភាពត្រឹមត្រូវនៃភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-271 តាមរយៈការសួរដេញដោលតទល់គ្នា រួមទាំង ភាពអាចជឿជាក់បាន និង ភាពទុកចិត្តបានរបស់គាត់[3]។

៤. នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ចម្លើយតបមួយទៅនឹងសំណើរបស់ នួន ជា ដោយស្នើសុំថា សំណើនេះគួរត្រូវបានបដិសេធចោលទាំងស្រុង[4]។ សហព្រះរាជអាជ្ញាបានឆ្លើយតបនៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ដោយស្នើសុំដល់អង្គជំនុំជម្រះឱ្យបដិសេធសំណើសុំរបស់ នួន ជា ដែរ[5]។

៥. ចំពោះដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-271 ដែលត្រូវបានកំណត់ពេលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងភ្លាម ក្រោយពេលសំណើសុំត្រូវបានដាក់រួចនោះ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចផ្ទាល់មាត់មួយនៅថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ដោយអង្គជំនុំជម្រះបានបដិសេធសំណើសុំរបស់ នួន ជា[6]។ តទៅនេះ អង្គជំនុំជម្រះសាលាដំបូងសូមចេញសំអាងហេតុពេញលេញសម្រាប់សេចក្តីសម្រេចរបស់ខ្លួន។

## ២. សារណា

### ២.១ ការអនុវត្តដែលអនុញ្ញាតឱ្យសាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណី (១) ពិនិត្យមើលចម្លើយពីមុនៗ មុននឹងផ្តល់សក្ខីកម្ម និង (២) ឆ្លើយសំណួរនាំមុខ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃចម្លើយជាលាយលក្ខណ៍អក្សរពីមុនៗរបស់ខ្លួន

---

[3] សំណើសុំរបស់ នួន ជា កថាខណ្ឌ ២០។

[4] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើរបស់មេធាវីការពារក្តី នួន ជា ពាក់ព័ន្ធនឹងការអនុវត្តមួយចំនួន នៅពេលសួរដេញដោលសាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ E336/1 ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ("ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី") កថាខណ្ឌ ១៣, ១៧, ២៧, ៣២, ៣៩។

[5] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា ពាក់ព័ន្ធនឹងការអនុវត្តមួយចំនួន នៅពេលសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-271 នាពេលខាងមុខ និង សាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងៗទៀតក្នុងសំណុំរឿង ០០២/០២ ឯកសារ E336/2 ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ កថាខណ្ឌ ៣, ៨ ("ចម្លើយតបរបស់សហព្រះរាជ-អាជ្ញា")។

[6] ប្រតិចារិកសវនាការ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ទំព័រ 78។ ចុងក្រោយ ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-271 បានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃទី ០៤ ដល់ ០៦ ខែ កុម្ភៈ និង ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៥។

៦. មេធាវីការពារក្តីលើកឡើងថា "គ្រប់ប្រភពច្បាប់ជាធរមានដែលពាក់ព័ន្ធទាំងអស់ហាមឃាត់" ការអនុវត្តនៃការបង្ហាញដល់សាក្សីនូវចម្លើយពីមុនៗរបស់ពួកគាត់ "រួមមានច្បាប់កម្ពុជា និង នីតិវិធីក្នុងប្រព័ន្ធច្បាប់ស៊ីវិលនៅកម្រិតអន្តរជាតិ"[7]។ មេធាវីការពារក្តីអះអាងថា តុលាការអន្តរជាតិបានទទួលស្គាល់ថា ការអនុវត្តនេះមិនស្របទៅនឹងការអនុវត្តតាមប្រព័ន្ធស៊ីវិលទេ ដែលវាបង្កើតឱ្យមានហានិភ័យក្នុងការកែប្រែការពិត ក្នុងករណីដែលអង្គហេតុកើតមានជាយូរមកហើយនោះ[8]។ មេធាវីការពារក្តីលើកឡើងថា សំអាងហេតុរបស់អង្គជំនុំជម្រះក្នុងការប្រកាន់យកការអនុវត្តនេះ ដែលថាសាក្សីអាចមានការលំបាកក្នុងការរម្លឹកឡើងវិញនូវចម្លើយរបស់ខ្លួន និងដើម្បីបញ្ចៀសការចំណាយពេលឥតប្រយោជន៍ក្នុងសវនាការមិនមែនជាការល្អទេ ហើយថាពេលវេលាត្រូវការដើម្បីឱ្យសាក្សីផ្ទៀងផ្ទាត់ចម្លើយពីមុនរបស់ខ្លួនមានត្រឹមតែប៉ុន្មាននាទីប៉ុណ្ណោះ[9]។ មេធាវីការពារក្តីលើកឡើងបន្ថែមទៀតថា ការអនុញ្ញាតឱ្យសាក្សីផ្តល់សក្ខីកម្មដោយបញ្ជាក់អំពីខ្លឹមសារនៃឯកសារដែលអាចឱ្យពួកគាត់ស្តាប់ដោយសហព្រះរាជអាជ្ញា "មិនត្រូវបានធ្វើយុត្តិកម្មដោយសារសំអាងហេតុ ឬមូលដ្ឋានសំអាងច្បាប់ណាមួយទេ ដែលសំអាងហេតុ ឬ មូលដ្ឋានទាំងនោះហាមឃាត់ការអនុវត្តនេះ ឬការពិចារណាដល់ប្រសិទ្ធភាព ឬ ការស្វែងរកការពិត"[10]។ ហេតុនេះ ពួកគេស្នើសុំថា ការអនុវត្តទាំងនេះគួរត្រូវបោះបង់ចោលក្នុងសវនាការលើសំណុំរឿង ០០២/០២ រួមទាំងក្នុងអំឡុងពេលស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-271 ផងដែរ[11]។

៧. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយតបថា ការអនុវត្តដែលអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីពិនិត្យឡើងវិញលើចម្លើយពីមុនរបស់ខ្លួនពុំមែនជាការខុសឆ្គងអ្វីនោះទេ ហើយថា សំណើសុំរបស់ នួន ជា មិនបានពន្យល់ច្បាស់ថា "អ្វីទៅដែលជាឧបសគ្គ" ឬ "មូលហេតុអ្វីដែលថាការអនុវត្តនេះមិនសមស្រប" នោះ[12]។

---

[7] សំណើសុំរបស់ នួន ជា កថាខណ្ឌ ៧។ *សូមមើលផងដែរ* ឯកសារ F16 បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ១៣៨ ដល់ ១៤៤។

[8] សំណើសុំរបស់ នួន ជា កថាខណ្ឌ ៧។ *សូមមើលផងដែរ* ប្រតិចារឹកសវនាការថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ២៧។

[9] សំណើសុំរបស់ នួន ជា កថាខណ្ឌ ៧។

[10] សំណើសុំរបស់ នួន ជា កថាខណ្ឌ ៨។

[11] សំណើរបស់ នួន ជា កថាខណ្ឌ ៦, ២០។

[12] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ២៨។

៨. សហព្រះរាជអាជ្ញាឆ្លើយតបថា ការអនុវត្តទាំងនេះគួរយកមកអនុវត្តនៅក្នុងសំណុំរឿង ០០២/០២ រហូតទាល់តែអង្គជំនុំជម្រះតុលាការកំពូលសម្រេចទៅលើបញ្ហានេះ[13]។ សហព្រះរាជអាជ្ញាឆ្លើយតបបន្ថែមថា មេធាវីការពារក្ដីយល់ខុសអំពីការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទិននឹងការប្រើប្រាស់ចម្លើយពីមុនៗរបស់សាក្សី[14]។

## ២.២ ការកម្រិតវិសាលភាពនៃការសួរតទល់របស់មេធាវីការពារក្ដី

៩. មេធាវីការពារក្ដី នួន ជា លើកឡើងថា ក្នុងអំឡុងពេលសវនាការលើសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូង "បន្តជ្រៀតជ្រែកដោយមិនត្រឹមត្រូវ" ទៅលើលទ្ធភាពរបស់មេធាវីការពារក្ដីក្នុងការតទល់ជាមួយសាក្សីដាក់បន្ទុក នួន ជា ដោយការដេញដោល*ក្នុងចំណោមនោះ* ដល់ភាពជឿជាក់បាន និង ភាពអាចទុកចិត្តបាននៃភស្តុតាងរបស់ពួកគេ ជាញឹកញយទាក់ទិននឹងលក្ខណៈនៃការទទួលបានភស្តុតាងនៅក្នុងកំណត់ហេតុនៃការស្ដាប់ចម្លើយជាលាយលក្ខណ៍អក្សរ ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ។ មេធាវីការពារក្ដី នួន ជា ស្នើសុំថា អង្គជំនុំជម្រះសាលាដំបូងគួរបោះបង់ចោលនូវការអនុវត្តដែលត្រូវបានចោទប្រកាន់នេះ[15]។

១០. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមិនបានធ្វើសេចក្ដីសន្និដ្ឋានណាមួយលើចំណុចនេះទេ ដោយកម្រិតការឆ្លើយតបរបស់ខ្លួនចំពោះវិធានការដែលពាក់ព័ន្ធនឹងដើមបណ្ដឹងរដ្ឋប្បវេណីប៉ុណ្ណោះ[16]។

១១. សហព្រះរាជអាជ្ញាបានឆ្លើយតបថា មេធាវីការពារក្ដី នួន ជា មិនបានបង្ហាញថា អង្គជំនុំជម្រះបានរារាំង ឬ បានដាក់កម្រិតហួសហេតុទៅលើលទ្ធភាពរបស់មេធាវីការពារក្ដី ក្នុងការសួរដេញដោលសាក្សី ឬ ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២/០២ ទេ[17]។

---

[13] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤។

[14] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥។

[15] សំណើសុំរបស់ នួន ជា កថាខណ្ឌ ៩ ដល់ ១០។ *សូមមើលផងដែរ* F16 បណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ១៤៨ ដល់ ១៥៣។

[16] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី កថាខណ្ឌ ១។

[17] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦។

## ២.៣ សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

១២. មេធាវីការពារក្ដីស្នើសុំថា អង្គជំនុំជម្រះគួរតម្រូវឱ្យដើមបណ្ដឹងរដ្ឋប្បវេណីផ្ដល់ភ័ស្តុតាងលើអង្គហេតុជាជាងផលប៉ះពាល់ទៅលើជនរងគ្រោះ ឬ សំណង។ ដើមបណ្ដឹងរដ្ឋប្បវេណីទាំងនោះត្រូវធ្វើសម្បថមុនពេលផ្ដល់សក្ខីកម្ម ហើយសហព្រះរាជអាជ្ញាជាអ្នកសួរដេញដោល[18]។ មេធាវីការពារក្ដីលើកឡើងនូវសំអាងហេតុជាច្រើន ដើម្បីគាំទ្រដល់សំណើនេះ។ ទីមួយ មេធាវីការពារក្ដីលើកឡើងថា តាមច្បាប់កម្ពុជា និង វិធានផ្ទៃក្នុង ដើមបណ្ដឹងរដ្ឋប្បវេណីមិនអាចត្រូវបានស្ដាប់សក្ខីកម្មក្នុងនាមជាសាក្សីទេ[19]។ ទីពីរ មេធាវីការពារក្ដីចោទប្រកាន់ថា ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានវត្តមាននៅចំពោះមុខអង្គជំនុំជម្រះ គឺអនុលោមតាមនីតិវិធីមួយដែលពុំមានការការពារសមស្របដល់សច្ចភាពនៃភ័ស្តុតាង ដោយសារពុំមានការតម្រូវឱ្យធ្វើសម្បថ ឬ ការហាមឃាត់មិនឱ្យទាក់ទងជាមួយមេធាវីមុនពេលផ្ដល់សក្ខីកម្ម[20]។ ទីបី មេធាវីការពារក្ដីអះអាងថា ដោយសារដើមបណ្ដឹងរដ្ឋប្បវេណីមិនតម្រូវឱ្យធ្វើសម្បថ ការនិយាយការពិតរបស់ពួកគេក៏អាចនឹងមានកំរិតធ្លាក់ចុះផងដែរ ហេតុនេះ ភ័ស្តុតាងរបស់ពួកគេគួរតែត្រូវបានចាត់ទុកថា អាចទុកចិត្តបានតិចតួច[21]។

១៣. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីឆ្លើយតបថា បញ្ហាថាតើដើមបណ្ដឹងរដ្ឋប្បវេណីគួរ ឬ មិនគួរធ្វើសម្បថ មុនពេលផ្ដល់សក្ខីកម្ម និង ថាតើអង្គជំនុំជម្រះសាលាដំបូងគួរផ្ដល់តម្លៃជាភ័ស្តុតាងដល់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឬ យ៉ាងណា ត្រូវបានសម្រេចដោយអង្គជំនុំជម្រះសាលាដំបូងរួចហើយ[22]។ ជាងនេះទៀត ពួកគេលើកឡើងថា វិធានផ្ទៃក្នុង និង យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងផ្ដល់ឋានៈពិសេសមួយដល់ដើមបណ្ដឹងរដ្ឋប្បវេណីខុសពីសាក្សី

[18] សំណើសុំរបស់ នួន ជា កថាខណ្ឌ ២០។

[19] សំណើសុំរបស់ នួន ជា កថាខណ្ឌ ១៣។

[20] សំណើសុំរបស់ នួន ជា កថាខណ្ឌ ១៤។ *សូមមើលផងដែរ* F16 បណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ២០១ ដល់ ២០៦។

[21] សំណើសុំរបស់ នួន ជា កថាខណ្ឌ ១៥ ដល់ ១៦។ *សូមមើលផងដែរ* F16 បណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ២០១, ២០៥។

[22] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី កថាខណ្ឌ ២, ៦ ដល់ ១៣។

01154419



ហើយហេតុនេះ សំណើសុំឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសម្បថ និង ហាមឃាត់មិនឱ្យពិនិត្យឡើងវិញទៅលើចម្លើយពីមុនៗរបស់ពួកគាត់ គឺជាការលើកឡើងដែលគ្មានមូលដ្ឋាន[23]។

១៤. ទាក់ទិននឹងការណ៍ដែលអង្គជំនុំជម្រះសាលាដំបូងសំអាងទៅលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីគាំទ្រដល់ការធ្វើសេចក្តីសន្និដ្ឋាននៅក្នុងសាលក្រម សហព្រះរាជអាជ្ញាឆ្លើយតបថា មេធាវីការពារក្តី នួន ជា មិនបានបង្ហាញពីកំហុសណាមួយនៅក្នុងវិធីសាស្ត្ររបស់អង្គជំនុំជម្រះនៅក្នុងសំណុំរឿង 00២/0២ ទេ ហើយថាទម្ងន់ និង តម្លៃនៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺជាបញ្ហាមួយដែលអង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើការកំណត់នៅពេលបញ្ចប់សវនាការ ដោយផ្អែកទៅលើភស្តុតាងពាក់ព័ន្ធទាំងអស់ដែលមាននៅក្នុងសំណុំរឿង[24]។

## ៣. ក្របខណ្ឌច្បាប់ និង សម្អាងហេតុ

១៥. ជាបញ្ហាបឋម អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សំណើ និង សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីទាក់ទិននឹងការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-271 ត្រួតគ្នាទៅនឹងសំណើ និង សេចក្តីសន្និដ្ឋានរបស់ខ្លួន ទាក់ទិននឹងការអនុវត្តជាទូទៅ។ អង្គជំនុំជម្រះសូមឆ្លើយតបទៅនឹងការអនុវត្តទូទៅដូចខាងក្រោម ដែលអនុវត្តចំពោះការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-271 ផងដែរ។

### ៣.១ ការអនុវត្តដែលអនុញ្ញាតឱ្យសាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណី (១) ពិនិត្យមើលចម្លើយពីមុនៗរបស់ខ្លួន មុននឹងផ្តល់សក្ខីកម្ម និង (២) ឆ្លើយសំណួរនាំមុខ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃចម្លើយជាលាយលក្ខណ៍អក្សរពីមុនៗរបស់ខ្លួន

១៦. អង្គជំនុំជម្រះធ្លាប់បានសម្រេចនៅក្នុងសំណុំរឿង 00២ ថា សាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានអនុញ្ញាតឱ្យពិនិត្យមើលចម្លើយពីមុនៗរបស់ខ្លួន មុននឹងផ្តល់សក្ខីកម្ម ហើយថា សាក្សីអាចនឹងត្រូវបានសួរឱ្យបញ្ជាក់ពីភាពត្រឹមត្រូវនៃចម្លើយពីមុនៗរបស់ខ្លួន[25]។ អង្គជំនុំជម្រះកត់សម្គាល់ថា

---

[23] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ២។

[24] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧។

[25] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា៖ "ការឆ្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និង ការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីច្បាប់ជាន់ខ្ពស់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២0១១" ឯកសារ E141 ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២0១១ ទំព័រ ៧។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងមានសេចក្តីសម្រេចលើសំណើសុំរបស់មេធាវីការពារក្តី នួន ជា ពាក់ព័ន្ធនឹងការអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូងនៅពេល

01154420



ពុំមានអង្គហេតុថ្មី ឬ កាលៈទេសៈថ្មីត្រូវបានបង្ហាញដោយភាគីដែលតម្រូវឱ្យអង្គជំនុំជម្រះងាកចេញពីទម្លាប់អនុវត្តបែបនេះឡើយ[26]។

១៧. អង្គជំនុំជម្រះរម្លឹកដល់ភាគីថា អនុលោមតាមក្របខណ្ឌច្បាប់នៅ អ.វ.ត.ក បុគ្គលភាគច្រើនត្រូវបានផ្តល់នូវកំណត់ហេតុស្តាប់ចម្លើយរបស់ខ្លួន នៅពេលសម្ភាសន៍ចប់។ វិធាន ២៥(២) នៃវិធានផ្ទៃក្នុងតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតផ្តល់ឱ្យបុគ្គលដែលត្រូវបានស្តាប់ចម្លើយ នូវចម្លើយរបស់ខ្លួនមួយច្បាប់ ក្នុងករណីដែលការស្តាប់ចម្លើយនោះមិនត្រូវបានធ្វើឡើងតាមរយៈការថតសំឡេង ឬថតរូបភាព។ ការពិនិត្យមើលទៅលើកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយនៅក្នុងសំណុំរឿង ០០២ ចង្អុលបង្ហាញថា នេះជាការអនុវត្តទូទៅ ទោះបីមិនមែនជាការអនុវត្តតែមួយដូចគ្នាក៏ដោយ[27]។ ជាងនេះទៅទៀត ដូចសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានកត់សម្គាល់រួចហើយ[28] ដើមបណ្តឹងរដ្ឋប្បវេណី និង មេធាវីរបស់ខ្លួនមានសិទ្ធិពិនិត្យ និង ទទួលបានឯកសារសំណុំរឿង អនុលោមតាមវិធាន ៨៦ នៃវិធានផ្ទៃក្នុង រួមទាំងចម្លើយពីមុនៗរបស់

ចំណងជើងថា៖ "ការប្រគល់ចម្លើយមុនៗដល់សាក្សីមុនពេលសាក្សីផ្តល់សក្ខីកម្មនៅសវនាការ" ឯកសារ E141/1 ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ២។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា៖ "សេចក្តីជូនដំណឹងទៅភាគីពាក់ព័ន្ធនឹងនីតិវិធីនៃការកែសម្រួលការសួរសំណួរ និង ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំការបំភ្លឺទាក់ទងនឹងការប្រើប្រាស់ឯកសារនានាក្នុងពេលស្តាប់សក្ខីកម្មសាក្សី (ឯកសារ E201)" ឯកសារ E201/2 ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ ទំព័រ ១។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា៖ "ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និង ការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ" ឯកសារ E218 ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ ៧។

[26] អង្គជំនុំជម្រះកត់សម្គាល់ថា ខ្លួនបានដោះស្រាយនៅក្នុងឯកសារ E355/3 នូវសំណើរួមគ្នារបស់ក្រុមមេធាវីការពារក្តីស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងប្រកាន់យកសេចក្តីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងការបើកការជំនុំជម្រះរបស់ខ្លួន។ សំណើសុំនេះបានទទួលមួយថ្ងៃបន្ទាប់ពីអង្គជំនុំជម្រះចេញសេចក្តីផ្ទាល់មាត់ទាក់ទិននឹងសំណើសុំរបស់ នួន ជា ហេតុនេះសំណើសុំនេះមិនត្រូវបានយកមកពិចារណានៅទីនេះទេ។

[27] *សូមមើលឧទាហរណ៍* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សាត ឯកសារ E3/4601 ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៥។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម អាឡាត់ ឯកសារ E3/4637 ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ៨។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀង ផាន ឯកសារ E3/419 ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៨។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សួង ស៊ីម ឯកសារ E3/4657 ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ១០។

[28] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៣១។

ដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ ហេតុនេះ ការអនុវត្តដែលអង្គភាពគាំពារសាក្សី និង អ្នកជំនាញ ផ្តល់នូវចម្លើយពីមុនៗទៅឱ្យបុគ្គលដែលមានវត្តមាននៅចំពោះមុខអង្គជំនុំជម្រះស្របទៅនឹងវិធាន ហើយការធ្វើដូចនេះ តែក្នុងករណីដែលចម្លើយពីមុនៗទាំងនេះបានបាត់ ឬ បុគ្គលដែលផ្តល់សក្ខីកម្ម រកមិនឃើញឯកសារប៉ុណ្ណោះ។ បន្ទាប់មកអង្គជំនុំជម្រះនឹងសួរបុគ្គលទាំងនេះឱ្យចង្អុលបង្ហាញថា តើពួកគេបានពិនិត្យទៅលើចម្លើយទាំងនេះ ឬ ទេ និង ថាតើពួកគេបញ្ជាក់ថាចម្លើយទាំងនោះពិត ឬ ទេ បញ្ចៀសកុំឱ្យមានការខ្ជះខ្ជាយពេលវេលាដ៏មានតម្លៃនៅពេលសវនាការ ដោយសារភាពច្រំដែល ដែលឥតប្រយោជន៍នៃចម្លើយដែលបានផ្តល់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតហើយនោះ[29]។

១៨. អង្គជំនុំជម្រះកត់សម្គាល់ថា ទោះបីមេធាវីការពារក្តីបានអះអាងថា "គ្រប់ប្រភពច្បាប់ជាធរមាន ដែលពាក់ព័ន្ធទាំងអស់ហាមឃាត់" ការអនុវត្តដែលផ្តល់ចម្លើយពីមុនៗទៅឱ្យសាក្សីក៏ដោយ ក៏ មេធាវីការពារក្តីមិនបានកំណត់អត្តសញ្ញាណប្រភពច្បាប់នានាដែលពិតជាហាមឃាត់ការអនុវត្តនេះ ដែរ។ នៅក្នុងរឿងក្តី *Lubanga* នៅតុលាការ ICC ដែលមេធាវីការពារក្តី នួន ជា យកមកសំអាង ដើម្បីគាំទ្រជំហររបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូង I បានសន្និដ្ឋានថា ការអនុវត្តឱ្យសាក្សីអាន ចម្លើយពីមុនៗរបស់ខ្លួននឹងជួយឱ្យការបង្ហាញភស្តុតាងមានប្រសិទ្ធផល និង ជួយអង្គជំនុំជម្រះ សាលាដំបូងក្នុងការស្វែងរកការពិត។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបានណែនាំឱ្យអង្គភាព គាំពារជនរងគ្រោះ និង សាក្សី ផ្តល់ចម្លើយពីមុនៗដែលមាន ដល់សាក្សីដើម្បីឱ្យពួកគេអាចរម្លឹកនូវ ការចងចាំរបស់ខ្លួន[30]។ ស្រដៀងគ្នាដែរ នៅក្នុងរឿងក្តី *Ruto និង Sang* និង រឿងក្តី *Muthaura និង Muigai* នៅតុលាការ ICC អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីណែនាំស្តីពីការត្រៀមរៀប ចំសវនាការ ដែលបានណែនាំឱ្យមេធាវីផ្តល់ឱកាសឱ្យសាក្សីពិនិត្យមើលចម្លើយពីមុនៗរបស់ខ្លួន មុននឹងមកបង្ហាញខ្លួននៅចំពោះមុខតុលាការ[31]។ ការអនុវត្តនៅតុលាការ ICTY ក៏ស្រដៀងគ្នាដែរ

---

[29] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា៖ "ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការដើម្បី ជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និង ការអនុវត្តវិធាន ការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ" ឯកសារ E218 ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ ៧។

[30] *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Lubanga* សេចក្តីសម្រេចទាក់ទិននឹងការអនុវត្តដែលត្រូវបានយកមកប្រើប្រាស់ដើម្បីត្រៀមរៀបចំ និង បន្សាំសាក្សីសម្រាប់ការផ្តល់សក្ខីកម្មនៅពេលសវនាការ សំណុំរឿងលេខ ICC-01/04-10/06 ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ៥០, ៥៥។

[31] *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Ruto និង Sang* ឧបសម្ព័ន្ធ៖ សេចក្តីណែនាំស្តីពីការត្រៀមរៀបចំសាក្សីសម្រាប់សវនាការសំណុំរឿង លេខ ICC-01/09-01/11-524-Anx ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ១៧។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Muthaura* សេចក្តីសម្រេចលើសំណើសុំរបស់មេធាវីការពារក្តី នួន ជា ពាក់ព័ន្ធនឹងការអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូងនៅពេល

ដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តី *Milutinović* សន្និដ្ឋានថា ការពិនិត្យមើលភស្តុតាងរបស់សាក្សីមុនពេលផ្តល់សក្ខីកម្មអាចជា "ការអនុវត្តដែលមានប្រយោជន៍" ត្រូវបានអនុញ្ញាត និង មិនប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទទេ[32]។ ដោយផ្អែកលើការពិនិត្យរបស់ខ្លួនទៅលើយុត្តិសាស្ត្រអន្តរជាតិ អង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា ការផ្តល់ឲ្យសាក្សីនូវចម្លើយពីមុនៗរបស់ខ្លួន មុនពេលពួកគាត់មកបង្ហាញខ្លួនក្នុងតុលាការ ស្របទៅនឹងការអនុវត្តជាអន្តរជាតិ។

## ៣.២ ការកម្រិតវិសាលភាពនៃការសួរដេញរបស់មេធាវីការពារក្តី

១៩. អង្គជំនុំជម្រះពិចារណាឃើញថា មេធាវីការពារក្តីមិនបានបង្ហាញថា អង្គជំនុំជម្រះបានដាក់កម្រិតហួសហេតុទៅលើលទ្ធភាពរបស់មេធាវីការពារក្តី ក្នុងការសួរដេញដោលសាក្សី ឬ ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២/០២ ទេ។

២០. អង្គជំនុំជម្រះសាលាដំបូងរម្លឹកភាគីថា អនុលោមតាមវិធាន ៨៥ និង ៨៧ នៃវិធានផ្ទៃក្នុង នៅក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះនឹងដកចេញនូវកិច្ចដំណើរការនីតិវិធី និង សំណួរនានាដែលអូសបន្លាយពេលសវនាការមិនចាំបាច់ ឬ មិនមានប្រយោជន៍ក្នុងការលាតត្រដាងការពិត។ ជាងនេះទៀត អង្គជំនុំជម្រះនឹងតាមដានវិសាលភាពនៃការសួរសំណួរពីភាគីទាំងអស់ ដើម្បីធានាថាការសួរសំណួររបស់ពួកគេមានភាពពាក់ព័ន្ធ ទន្ទឹមនឹងនោះធានាបាននូវការអនុវត្តសិទ្ធិការពារក្តីដោយសេរី។

## ៣.៣ សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី

២១. ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក ជួយឲ្យជនរងគ្រោះអាចចូលរួមជាភាគីនៅក្នុងការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌចំពោះជនជាប់ចោទ និង ស្នើសុំសំណងផ្លូវចិត្ត និង ជាសមូហភាព ចំពោះព្យសនកម្មដែលបានទទួលរងដោយសារបទឧក្រិដ្ឋ ប្រសិនបើជនជាប់ចោទ

---

*និង Muigai* ឧបសម្ព័ន្ធ៖ សេចក្តីណែនាំស្តីពីការត្រៀមរៀបចំសាក្សីសម្រាប់សវនាការ សំណុំរឿងលេខ ICC-01/09-02/11-588-Anx ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ១៧។

[32] *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Milutinović និង អ្នកផ្សេងទៀត* សេចក្តីសម្រេចលើសំណើរបស់ Ojdanić ដែលសុំឲ្យហាមឃាត់សាក្សីមិនឲ្យបង្ហាញភស្តុតាង សំណុំរឿងលេខ IT-05-87-T ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៦ កថាខណ្ឌ ២០, ២២។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Haradinaj និង អ្នកផ្សេងទៀត* សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំខ្សែអាត់ថតសំឡេងនៃសវនាការផ្តល់ភស្តុតាងរបស់សាក្សីជាក់បន្ទុក សំណុំរឿងលេខ IT-04-84-T ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៧ កថាខណ្ឌ ៨, ១៤។

ត្រូវបានផ្តន្ទាទោស[33]។ ដូចដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានកត់សម្គាល់ថា ក្របខណ្ឌច្បាប់ អ.វ.ត.ក ផ្តល់ឋានៈពិសេសមួយដល់ដើមបណ្តឹងរដ្ឋប្បវេណីខុសពីសាក្សី។ វិធាន ២៣(៤), ២៤ និង ៣១ នៃវិធានផ្ទៃក្នុង ចង្អុលបង្ហាញថា បុគ្គលជាសាក្សីទាំងនោះដែលមកបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក ត្រូវធ្វើសម្បថទៅតាមការកំណត់នៅក្នុងក្របខណ្ឌច្បាប់ អ.វ.ត.ក។ ពុំមានលក្ខខណ្ឌតម្រូវបែបនេះចំពោះដើមបណ្តឹងរដ្ឋប្បវេណីទេ (ឬភាគីផ្សេងទៀតនៃកិច្ចដំណើរការនីតិវិធី រួមមានជនជាប់ចោទ និង សាច់ញាតិជិតស្និទ្ធរបស់ពួកគេ)[34]។ ការអនុវត្តនេះត្រូវបានទទួលយករួចមកហើយនៅក្នុងសំណុំរឿង ០០១ និង ០០២ ទាំងមូល[35]។ ចំណុចនេះបង្កើតនូវលក្ខណៈពិសេសមួយនៃច្បាប់កម្ពុជា និង ច្បាប់ជាតិផ្សេងទៀតជាច្រើននៅបណ្តាប្រទេសដែលប្រកាន់យកការធ្វើជាតំណាងជនរងគ្រោះតាមរយៈប្រព័ន្ធច្បាប់ស៊ីវិល[36]។

២២. ទាក់ទិននឹងអំណះអំណាងរបស់មេធាវីការពារក្តីដែលថា ទម្ងន់ និង តម្លៃជាភ័ស្តុតាងអាចត្រូវបានប៉ះពាល់ដោយសារពុំមានការការពារផ្នែកនីតិវិធី ដូចជាលក្ខខណ្ឌតម្រូវឱ្យធ្វើសម្បថជាដើមនោះ អង្គជំនុំជម្រះកត់សម្គាល់ថា អង្គជំនុំជម្រះនឹងសម្រេចទៅលើទម្ងន់ និង តម្លៃជាភ័ស្តុតាងនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅតាមករណីនីមួយៗ ដោយពិនិត្យទៅលើភាពអាចជឿជាក់បាននៃសក្ខីកម្មនោះ នៅដំណាក់កាលសមស្របនៃរឿងក្តី[37]។ នៅគ្រប់កាលៈទេសៈទាំងអស់ ការអនុវត្តនេះអនុញ្ញាតឱ្យអង្គជំនុំជម្រះអាចវាយតម្លៃពីភាពពេញលេញ និង គុណភាពនៃភ័ស្តុតាង និង ការប្រើប្រាស់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីគាំទ្រដល់សម្អាងហេតុជាក់លាក់ណាមួយក្នុង

---

[33] វិធាន ២៣(១) នៃវិធានផ្ទៃក្នុង។

[34] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា៖ "ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើសុំលេខ E67, E57, E56, E58, E23, E59, E20, E33, E71 និង E73 ក្រោយកិច្ចប្រជុំរៀបចំសវនាការថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១" ឯកសារ E74 ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១១ ទំព័រ ២។

[35] *សូមមើល ឧទាហរណ៍* ប្រតិចារឹកសវនាការថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ ទំព័រ ២, ៥១ ដល់ ៩១។

[36] ឧទាហរណ៍ មាត្រា ៩៣ និង ៣១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌសេនេហ្គាល់ ដែលអនុវត្តនៅអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការអាហ្វ្រិក។

[37] សេចក្តីសម្រេចលើសំណើសុំកោះហៅសាជាថ្មីដើមបណ្តឹងរដ្ឋប្បវេណី TCCP-187 និង សុំពិនិត្យឡើងវិញលើបែបបទពាក់ព័ន្ធនឹងសក្ខីកម្មស្តីពីទុក្ខសោកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំង សំណើសុំ និង ចម្លើយតបនានាដែលពាក់ព័ន្ធ (ឯកសារ E240, E240/1, E250, E250/1, E267, E267/1 និង E267/2) ឯកសារ E267/3 ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ កថាខណ្ឌ ២២។

ករណីសមស្រប។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីលើចំណុចនេះមិនត្រឹមត្រូវទេ។

**តាមសំអាងហេតុនានាដែលបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូង សម្រេចៈ**

**បដិសេធ** សំណើសុំរបស់មេធាវីការពារក្ដី នួន ជា ទាំងស្រុង។

ភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**និល ណុន**